**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**

**អំពើជួញដូរមនុស្ស**

លេខ: ០៩៥/២៤ ល.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការប្រគល់ និងកែសម្រួលភារកិច្ច

**អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៣៧ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីគោលការណ៍សម្រាប់ការតែងតាំងទីប្រឹក្សា និងជំនួយការ នៅក្នុងអង្គការនីតិប្រតិបត្តិ
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញប្រកាសលេខ ០០១/១៥ប្រក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ការិយាល័យចំណុះលេខាធិការដ្ឋានរដ្ឋបាលសរុប នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- យោងតាមការចាំបាច់របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

## សម្រេច

**ប្រការ១.–**

ត្រូវបានប្រគល់ និងកែសម្រួលភារកិច្ច ជូន អគ្គលេខាធិការរងចំនួន ០៩រូប និងទីប្រឹក្សា នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន ០៥រូប មានរាយនាមដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តមឧត្តមសេនីយ៍ឯក | **ខៀវ ចាន់រ៉ា** | អគ្គលេខាធិការរង ទទួលជួយអគ្គលេខាធិការ ដឹកនាំក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ និងការិយាល័យអប់រំ និងផ្សព្វផ្សាយ |
| ២-ឯកឧត្តមឧត្តមសេនីយ៍ឯក | **យ៉ែម ច័ន្ទណារុំ** | អគ្គលេខាធិការរង ទទួលជួយអគ្គលេខាធិការ ដឹកនាំការិយាល័យសរុបផែនការ និងតាមដានការអនុវត្ត កិច្ចព្រមព្រៀង អនុស្សរណៈ ទ្វេភាគី និងពហុភាគី ជាមួយប្រទេសពាក់ព័ន្ធ |
| ៣-ឯកឧត្តមឧត្តមសេនីយ៍ឯក | **លី តុងហ៊ុយ** | អគ្គលេខាធិការរង ទទួលជួយអគ្គលេខាធិការ ដឹកនាំក្រុមជំនួយកិច្ចការការពារជនរងគ្រោះ |

| | | |
|---|---|---|
| ៤-ឯកឧត្តមឧត្តមសេនីយ៍ឯក | អ៊ូ ម៉ានីវ៉ា | អគ្គលេខាធិការរង ទទួលជួយអគ្គលេខាធិការក្នុងការពិនិត្យ តាមដាន ការអនុវត្តអនុស្សរណៈយោគយល់ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយអង្គការដៃគូ |
| ៥-លោកជំទាវឧត្តមសេនីយ៍ទោ | វ៉ែន សិរីលក្ខិណា | អគ្គលេខាធិការរង ទទួលជួយអគ្គលេខាធិការដឹកនាំក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ និងការិយាល័យ ស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ |
| ៦-ឯកឧត្តមឧត្តមសេនីយ៍ទោ | នី គឹមស្រេន | អគ្គលេខាធិការរង ទទួលជួយអគ្គលេខាធិការដឹកនាំក្រុមជំនួយកិច្ចការយុត្តិធម៌ និងការិយា-ល័យផែនការហិរញ្ញកិច្ច និងភស្តុភារ |
| ៧-ឯកឧត្តមឧត្តមសេនីយ៍ទោ | កែវ សុវណ្ណារ៉ា | អគ្គលេខាធិការរង ទទួលជួយអគ្គលេខាធិការដឹកនាំក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់ |
| ៨-លោកជំទាវឧត្តមសេនីយ៍ទោ | ស៊ឹម ផាណុំ | អគ្គលេខាធិការរង ទទួលជួយអគ្គលេខាធិការដឹកនាំការងារយេនឌ័រ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងការិយាល័យរដ្ឋបាល |
| ៩-ឯកឧត្តមឧត្តមសេនីយ៍ត្រី | តែ សុថារេត | អគ្គលេខាធិការរង ទទួលជួយអគ្គលេខាធិការដឹកនាំក្រុមជំនួយកិច្ចការអនុវត្តច្បាប់ |
| ១០-លោក | កែប សារឿន | ទីប្រឹក្សា ទទួលជួយអគ្គលេខាធិការលើការងាររបាយការណ៍ និងការងារដែលអគ្គលេខាធិការប្រគល់ជូន |
| ១១-លោក | កែវ ផល្លា | ទីប្រឹក្សា ទទួលជួយអគ្គលេខាធិការ លើការងាររបាយការណ៍ និងការងារដែលអគ្គលេខាធិការប្រគល់ជូន |
| ១២-លោក | អៀង ប៊ុនថន | ទីប្រឹក្សា ទទួលជួយអគ្គលេខាធិការលើការងារផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព របស់គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការងារដែលអគ្គលេខាធិការប្រគល់ជូន |
| ១៣-លោក | គួច គឹមហៀក | ទីប្រឹក្សា ទទួលជួយអគ្គលេខាធិការ ប្រមូល ចងក្រង ព័ត៌មានពាក់ព័ន្ធ នឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមប្រព័ន្ធបណ្តាញសង្គម និងតាមសារព័ត៌មាននានា និងការងារដែលអគ្គលេខាធិការប្រគល់ជូន |
| ១៤-លោក | ដៀប នូច | ទីប្រឹក្សា ទទួលជួយអគ្គលេខាធិការ ប្រមូល ចងក្រង រូបភាពក្នុងកិច្ចប្រជុំ កម្មវិធីផ្សេងៗ និងការងារដែលអគ្គលេខាធិការប្រគល់ជូន។ |

**ប្រការ២.** –

ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង លោកទីប្រឹក្សា ដូចមានរាយនាមក្នុងប្រការ១ ត្រូវទំនាក់ទំនង និងសហការ ជាមួយអង្គភាព ការិយាល័យពាក់ព័ន្ធ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីធ្វើឱ្យសម្រេចភារកិច្ច ដែលបានប្រគល់ជូន ដោយគោរពស្នើសុំគោលការណ៍ និងរាយការណ៍ជូន អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តាមរយៈ អគ្គលេខាធិការ ។

**ប្រការ៣.** –

សេចក្តីសម្រេចរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.** –

អគ្គលេខាធិការ ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប ប្រធានក្រុមជំនួយកិច្ចការទាំង៦ នៃ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ការិយាល័យចំណុះលេខាធិការដ្ឋានរដ្ឋបាលសរុប និងសាមីខ្លួនដូចមានរាយ នាមក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃចន្ទ ១១កើត ខែ ជេស្ឋ ឆ្នាំរោង ឆស័កព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៤

**អនុប្រធានអចិន្ត្រៃយ៍**

ជុំ ប៊ុនអេង

***ចម្លងជូន៖***

- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- ក្រុមជំនួយកិច្ចការនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- លេខាធិការដ្ឋានរដ្ឋបាលសរុប
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ